**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ៧៤២ សហវ.ប្រក

# ប្រកាស
## ស្តីពី
## ប្រាក់កក់ធានាការដេញថ្លៃនិងប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា

## ទេសរដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី ២១ ខែធ្នូ ឆ្នាំ ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១១/០១១ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីរបបហិរញ្ញវត្ថុនិងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១២/០០៤ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលទ្ធកម្មសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី ១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១០៥ អនក្រ.បក ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០០៦ ស្តីពីលទ្ធកម្មសាធារណៈ
- បានឃើញអនុក្រឹត្យលេខ១៣ អនក្រ.បក ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១៥ ស្តីពីនីតិវិធីនៃការបង្កើត ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការលទ្ធកម្ម និងអង្គភាពលទ្ធកម្ម
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, khan Daun Penh, Phnom Penh, CAMBODIA.
ទូរសព្ទ័ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

## សម្រេច

**ប្រការ១.-**

ប្រកាសនេះមានគោលបំណងរួមចំណែកធានានូវប្រសិទ្ធភាពនៃការដេញថ្លៃនិងការអនុវត្តកិច្ចសន្យាក្នុងកិច្ចលទ្ធកម្មសាធារណៈ។

**ប្រការ២.-**

ប្រកាសនេះមានគោលដៅកំណត់អំពីទម្រង់ ចំនួនទឹកប្រាក់ នីតិវិធីនៃការកក់ប្រាក់និងការដកប្រាក់កក់ និងវិធានការចំពោះអ្នកដេញថ្លៃ អ្នកផ្គត់ផ្គង់ ឬ អ្នកទទួលការ ដែលមិនអនុវត្តតាមលក្ខខណ្ឌតម្រូវក្នុងឯកសារដេញថ្លៃ និងលក្ខខណ្ឌនៃកិច្ចសន្យា។

**ប្រការ៣.-**

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះគ្រប់វិធីសាស្ត្រលទ្ធកម្ម លើកលែងតែ÷

- វិធីសាស្ត្រស្ទង់តម្លៃ វិធីសាស្ត្រជ្រើសរើសទីប្រឹក្សាឯកត្តជន និងវិធីសាស្ត្រលទ្ធកម្មដោយឡែកដែលមិនតម្រូវឲ្យកក់ប្រាក់ធានាការដេញថ្លៃ។
- វិធីសាស្ត្រស្ទង់តម្លៃ វិធីសាស្ត្រជ្រើសរើសទីប្រឹក្សាឯកត្តជន និងវិធីសាស្ត្រលទ្ធកម្មដោយឡែកសម្រាប់ការចុះកិច្ចសន្យាជាមួយអង្គភាពជំនាញនៃស្ថាប័នរដ្ឋនិងការចុះកិច្ចសន្យាជាមួយនឹងសហគមន៍ ដែលមិនតម្រូវឲ្យកក់ប្រាក់ធានាការអនុវត្តកិច្ចសន្យា។

**ប្រការ៤.-**

ប្រាក់កក់ធានាការដេញថ្លៃត្រូវមានចំនួនស្មើនឹង២%នៃទឹកប្រាក់ធានាចំណាយ រីឯប្រាក់កក់ធានាការអនុវត្តកិច្ចសន្យាត្រូវមានចំនួនស្មើនឹង១០%នៃតម្លៃកិច្ចសន្យា។

ការគណនាចំនួនប្រាក់កក់ធានាការដេញថ្លៃនិងប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា ត្រូវបង្គ្រប់ជាលេខគត់ខ្ទង់រយ។

**ប្រការ៥.-**

ប្រាក់កក់ធានាការដេញថ្លៃនិងប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា អាចកក់ចូលគណនីប្រាក់កក់របស់អគ្គនាយកដ្ឋានរតនាគារជាតិ ឬរតនាគាររាជធានី ខេត្ត បើកនៅធនាគារជាតិនៃកម្ពុជា ឬកក់នៅធនាគារពាណិជ្ជដៃគូណាមួយដែលបានចុះអនុស្សរណៈនៃការយោគយល់គ្នាជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**ប្រការ៦.-**

អគ្គនាយកដ្ឋានរតនាគារជាតិ រតនាគាររាជធានី ខេត្ត ឬធនាគារពាណិជ្ជដៃគូ ត្រូវចេញលិខិតធានាប្រាក់កក់ធានាការដេញថ្លៃ ឬលិខិតធានាប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា ជូនស្ថាប័នអនុវត្តលទ្ធកម្ម ឬអង្គភាពថវិកា។

**ប្រការ៧.-**

លិខិតធានាប្រាក់កក់ធានាការដេញថ្លៃត្រូវមានសុពលភាពរយៈពេល៣០ថ្ងៃយ៉ាងតិច បន្ទាប់ពីផុតសុពលភាពនៃសំណើដេញថ្លៃ។ ក្នុងករណីមានការពន្យារពេលសុពលភាពនៃសំណើដេញថ្លៃ នោះសុពលភាពនៃលិខិតធានាប្រាក់កក់ធានាការដេញថ្លៃក៏ត្រូវបានពន្យារពេលស្របគ្នាផងដែរ។

លិខិតធានាប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា ត្រូវមានសុពលភាពរហូតដល់ការប្រគល់ទទួលគ្រប់ចំនួន ឬរហូតដល់ផុតសុពលភាពធានាគុណភាពទំនិញ សំណង់ ឬសេវា។

**ប្រការ៨.-**

អ្នកដេញថ្លៃត្រូវភ្ជាប់ជាមួយសំណើដេញថ្លៃនូវលិខិតធានាប្រាក់កក់ធានាការដេញថ្លៃ។ សំណើដេញថ្លៃណាដែលមិនមានភ្ជាប់មកជាមួយនូវលិខិតធានាប្រាក់កក់ធានាការដេញថ្លៃ ឬមានលិខិតធានាប្រាក់កក់ធានាការដេញថ្លៃដែលមានទឹកប្រាក់តិចជាង២%នៃទឹកប្រាក់ធានាចំណាយ សំណើដេញថ្លៃនោះនឹងត្រូវបានបដិសេធ។

**ប្រការ៩.-**

ក្នុងរយៈពេល ០៧ (ប្រាំពីរ) ថ្ងៃនៃថ្ងៃធ្វើការយ៉ាងយូរបន្ទាប់ពីទទួលបានលិខិតស្តីពីការអញ្ជើញចុះកិច្ចសន្យា អ្នកដេញថ្លៃឈ្នះត្រូវផ្តល់នូវលិខិតធានាប្រាក់កក់ធានាការអនុវត្តកិច្ចសន្យាជូនស្ថាប័នអនុវត្តលទ្ធកម្ម ឬអង្គភាពថវិកា ដើម្បីដំណើរការចុះកិច្ចសន្យា។ ការខកខានរបស់អ្នកដេញថ្លៃឈ្នះក្នុងការផ្តល់លិខិតធានាប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា គឺជាមូលដ្ឋានគ្រប់គ្រាន់ក្នុងការចាត់ទុកជាមោឃៈនៃការសម្រេចប្រគល់កិច្ចសន្យា ហើយអ្នកដេញថ្លៃឈ្នះនោះនឹងត្រូវបានកត់ត្រាក្នុងបញ្ជីខ្មៅ។

**ប្រការ១០.-**

ប្រាក់កក់ធានាការដេញថ្លៃនឹងត្រូវរឹបអូសបង់ចូលថវិការដ្ឋប្រសិនបើ÷

- អ្នកដេញថ្លៃសុំដកសំណើដេញថ្លៃរបស់ខ្លួនវិញក្នុងរយៈពេលសុពលភាពនៃសំណើដេញថ្លៃ
- អ្នកដេញថ្លៃឈ្នះមិនព្រមផ្តល់លិខិតធានាប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា
- អ្នកដេញថ្លៃឈ្នះមិនព្រមចុះកិច្ចសន្យាក្នុងរយៈពេលដែលបានកំណត់ក្នុងលិខិតស្តីពីការអញ្ជើញចុះកិច្ចសន្យា

ប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា នឹងត្រូវរឹបអូសបង់ចូលថវិការដ្ឋ ប្រសិនបើអ្នកផ្គត់ផ្គង់ឬអ្នកទទួលការមិនអនុវត្តតាមលក្ខខណ្ឌណាមួយនៃកិច្ចសន្យា ហើយត្រូវបានស្ថាប័នអនុវត្តលទ្ធកម្ម ឬអង្គភាពថវិកាបញ្ចប់កិច្ចសន្យាជាស្ថាពរ។

ករណីមានការរឹបអូសប្រាក់កក់ធានាការដេញថ្លៃ ឬប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា ស្ថាប័នអនុវត្តលទ្ធកម្ម ឬអង្គភាពថវិកាដែលមិនមែនជាសហគ្រាសសាធារណៈ និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវចេញលិខិតជូនដំណឹងស្តីពីការរឹបអូសប្រាក់កក់ធានាការដេញថ្លៃ ឬប្រាក់កក់ធានាការអនុវត្តកិច្ចសន្យាទៅ÷

- អគ្គនាយកដ្ឋានរតនាគារជាតិ ឬរតនាគាររាជធានី ខេត្ត ដើម្បីបង្វែរប្រាក់កក់នោះចូលថវិការដ្ឋ ឬ
- ធនាគារពាណិជ្ជដៃគូដើម្បីបង់សាច់ប្រាក់តាមចំនួនដែលចែងក្នុងលិខិតធានា (Bank Guarantee) របស់ខ្លួនចូលគណនីទោលរតនាគារ ដើម្បីបង្វែរចូលថវិការដ្ឋ។

ចំពោះស្ថាប័នអនុវត្តលទ្ធកម្មដែលជាសហគ្រាសសាធារណៈ និងគ្រឹះស្ថានសាធារណៈរដ្ឋបាល នៅពេលមានករណីរឹបអូសប្រាក់កក់ធានាការដេញថ្លៃ ឬប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា ត្រូវចេញលិខិតជូនដំណឹងស្តីពីការរឹបអូសប្រាក់កក់ធានាការដេញថ្លៃ ឬប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា ទៅអគ្គនាយកដ្ឋានរតនាគារជាតិ ឬរតនាគាររាជធានី ខេត្ត ឬធនាគារពាណិជ្ជដៃគូដើម្បីបង្វិលប្រាក់កក់ដែលត្រូវរឹបអូសនោះចូលគណនីរបស់ខ្លួន។

**ប្រការ១១.-**

ក្នុងរយៈពេល៥(ប្រាំ)ថ្ងៃនៃថ្ងៃធ្វើការយ៉ាងយូរ បន្ទាប់ពីអ្នកដេញថ្លៃឈ្នះបានចុះកិច្ចសន្យានិងកក់ប្រាក់ធានាការអនុវត្តកិច្ចសន្យា ស្ថាប័នអនុវត្តលទ្ធកម្ម ឬអង្គភាពថវិកា ត្រូវចេញលិខិតជូនដំណឹងស្តីពីការអនុញ្ញាតដកប្រាក់កក់ធានាការដេញថ្លៃទៅអគ្គនាយកដ្ឋានរតនាគារជាតិ ឬរតនាគាររាជធានី ខេត្ត ឬធនាគារពាណិជ្ជដៃគូ ដើម្បីបង្វិលប្រាក់កក់ធានាការដេញថ្លៃជូនអ្នកដេញថ្លៃវិញ។

ក្នុងរយៈពេល៥(ប្រាំ)ថ្ងៃនៃថ្ងៃធ្វើការយ៉ាងយូរ បន្ទាប់ពីការប្រគល់ទទួលទំនិញ សំណង់ ឬសេវាគ្រប់ចំនួន ឬបន្ទាប់ពីផុតសុពលភាពធានាគុណភាពទំនិញ សំណង់ ឬសេវា ស្ថាប័នអនុវត្តលទ្ធកម្ម ឬអង្គភាពថវិកាត្រូវផ្ញើលិខិតជូនដំណឹងស្តីពីការអនុញ្ញាតដកប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា ទៅអគ្គនាយកដ្ឋានរតនាគារជាតិ ឬរតនាគាររាជធានី ខេត្ត ឬធនាគារពាណិជ្ជដៃគូ ដើម្បីបង្វិលប្រាក់កក់ធានាការអនុវត្តកិច្ចសន្យាជូនអ្នកផ្គត់ផ្គង់ ឬអ្នកទទួលការវិញ។

**ប្រការ១២.-**

ស្ថាប័នអនុវត្តលទ្ធកម្ម ឬអង្គភាពថវិកាត្រូវចម្លងលិខិតជូនដំណឹងស្តីពីការអនុញ្ញាតដកប្រាក់កក់ធានាការដេញថ្លៃ ឬប្រាក់កក់ធានាការអនុវត្តកិច្ចសន្យាដូចមានចែងក្នុងប្រការ១១ខាងលើ ជូនអ្នកដេញថ្លៃ ឬអ្នកផ្គត់ផ្គង់ ឬអ្នកទទួលការ ដើម្បីទៅដកប្រាក់កក់របស់ខ្លួនវិញ។

**ប្រការ១៣.-**

គំរូលិខិតធានាប្រាក់កក់ធានាការដេញថ្លៃ លិខិតធានាប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា លិខិតជូនដំណឹងស្តីពីការអនុញ្ញាតដកប្រាក់កក់ធានាការដេញថ្លៃ លិខិតជូនដំណឹងស្តីពីការអនុញ្ញាតដកប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា លិខិតជូនដំណឹងស្តីពីការរឹបអូសប្រាក់កក់ធានាការដេញថ្លៃ និងគំរូលិខិតជូនដំណឹងស្តីពីការរឹបអូសប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា ត្រូវបានកំណត់ជាឧបសម្ព័ន្ធនៃប្រកាសនេះ។

**ប្រការ១៤.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ១៥.-**

រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ប្រធានសហគ្រាសសាធារណៈ ប្រធានគ្រឹះស្ថានសាធារណៈរដ្ឋបាល ប្រធានអង្គភាពថវិកា និងប្រធានអង្គភាពចំណុះក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវអនុវត្តប្រកាសនេះឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០១៦ នេះតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី៣១ខែសីហា ឆ្នាំ ២០១៦

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល៖**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី "ដើម្បីជូនជ្រាប"
- ដូចក្នុងប្រការ១៥ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ឧបសម្ព័ន្ធទី ១

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**អគ្គនាយកដ្ឋានរតនាគារជាតិ/រតនាគារ/ធនាគារ......**

# លិខិតធានា
# ប្រាក់កក់ធានាការដេញថ្លៃ

**សូមគោរពជូន**
**ឯកឧត្តម/លោកជំទាវ/លោក/លោកស្រី ប្រធានគណៈកម្មាធិការលទ្ធកម្ម/ក្រុមលទ្ធកម្ម....**

ដោយហេតុថាក្រុមហ៊ុន/សហគ្រាស ........................................ មានបំណងដាក់សំណើដេញថ្លៃ ដើម្បីធ្វើការផ្គត់ផ្គង់/ សាងសង់/ ជួសជុល/ សេវា...................... ដែលត្រូវបើកសំណើដេញថ្លៃនៅថ្ងៃទី......... ខែ........ ឆ្នាំ.................. ។

អគ្គនាយកដ្ឋានរតនាគារជាតិ/រតនាគារ/ធនាគារ........... សូមធានាចំពោះមុខប្រធានគណៈកម្មាធិការលទ្ធកម្ម/ក្រុមលទ្ធកម្ម ........................................... នូវប្រាក់កក់ធានាការដេញថ្លៃចំនួន .................................. (សរសេរជាអក្សរ ...................................) ។

ក្នុងករណីមានលក្ខខណ្ឌណាមួយកើតមានឡើងក្នុងចំណោមលក្ខខណ្ឌទាំងបីខាងក្រោម ÷

១-ប្រសិនបើអ្នកដេញថ្លៃ ដកសំណើដេញថ្លៃរបស់ខ្លួន ក្នុងរយៈពេលសុពលភាពនៃសំណើដេញថ្លៃ

២-ប្រសិនបើអ្នកដេញថ្លៃ មិនព្រមកក់ប្រាក់ធានាការអនុវត្តកិច្ចសន្យា

៣-ប្រសិនបើអ្នកដេញថ្លៃ បដិសេធការចុះហត្ថលេខាលើកិច្ចសន្យា ក្នុងរយៈពេលសុពលភាពនៃសំណើដេញថ្លៃ

នោះអគ្គនាយកដ្ឋានរតនាគារជាតិ/រតនាគារ/ធនាគារ........... នឹងធ្វើការរឹបអូសបង់ចូលថវិការដ្ឋនូវចំនួនប្រាក់កក់ខាងលើ នៅពេលដែលបានទទួលលិខិតស្នើសុំពីប្រធានគណៈកម្មាធិការលទ្ធកម្ម/ក្រុមលទ្ធកម្ម...... ដែលបញ្ជាក់ថាអ្នកដេញថ្លៃមិនគោរពតាមលក្ខខណ្ឌណាមួយក្នុងចំណោមលក្ខខណ្ឌទាំងបីខាងលើ ។

លិខិតធានាប្រាក់កក់ធានាការដេញថ្លៃនេះមានសុពលភាព រយៈពេលយ៉ាងតិចសាមសិប(៣០)ថ្ងៃក្រោយសុពលភាពសំណើដេញថ្លៃ ។

................. ថ្ងៃទី.............. ខែ ..............

**អគ្គនាយកដ្ឋានរតនាគារជាតិ/រតនាគារ/ធនាគារ......**

ឧបសម្ព័ន្ធទី ២

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**អគ្គនាយកដ្ឋានរតនាគារជាតិ/រតនាគារ/ធនាគារ.........**

# លិខិតធានា

## ប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា

**សូមគោរពជូន**

**ឯកឧត្តម/លោកជំទាវ/លោក/លោកស្រី ប្រធានគណៈកម្មាធិការលទ្ធកម្ម/ក្រុមលទ្ធកម្ម..............**

ដោយហេតុថាក្រុមហ៊ុន/សហគ្រាស ............................................................ បានទទួលលិខិតស្តីពីការចុះកិច្ចសន្យាការផ្គត់ផ្គង់/សាងសង់/ជួសជុល/សេវា...................... លេខ ............. ចុះថ្ងៃទី ...... ខែ ........ ឆ្នាំ.............ដែលមានតម្លៃកិច្ចសន្យាចំនួន............................(សរសេរជាអក្សរ .......................................) ។

ដោយមានចែងនៅក្នុងលិខិតស្តីពីការចុះកិច្ចសន្យាថា **អ្នកផ្គត់ផ្គង់/អ្នកទទួលការ** ត្រូវផ្តល់លិខិតធានាប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា ចេញដោយអគ្គនាយកដ្ឋានរតនាគារជាតិ/រតនាគារ/ធនាគារ ............. ដែលមានតម្លៃទឹកប្រាក់ស្មើនឹង១០% (ដប់ភាគរយ) នៃតម្លៃកិច្ចសន្យា ដើម្បីធានាការអនុវត្តកាតព្វកិច្ចស្របតាមលក្ខខណ្ឌនៃកិច្ចសន្យា ។

អគ្គនាយកដ្ឋានរតនាគារជាតិ/រតនាគារ/ធនាគារ.............សូមធានា និងទទួលខុសត្រូវ នូវប្រាក់កក់ចំនួន ......................... (សរសេរជាអក្សរ ................................................ )។

ប្រាក់កក់ខាងលើនេះ នឹងត្រូវរឹបអូសបង់ចូលថវិការដ្ឋ នៅពេលបានទទួលលិខិតស្នើសុំពី **អ្នកទិញ/អ្នកម្ចាស់ការ** ដែលបញ្ជាក់ថា **អ្នកផ្គត់ផ្គង់/អ្នកទទួលការ** មិនគោរពតាមលក្ខខណ្ឌនៃកិច្ចសន្យា ហើយក្រុមហ៊ុន/សហគ្រាស .............................. គ្មានសិទ្ធិប្រកែក ឬតវ៉ាឡើយ ។

លិខិតធានានេះមានសុពលភាពរហូតដល់ ក្រោយថ្ងៃប្រគល់ ទទួលទំនិញគ្រប់ចំនួន ឬក្រោយរយៈពេលធានាគុណភាពទំនិញ សំណង់ សេវា ។

.......,ថ្ងៃទី.....ខែ......ឆ្នាំ.......

**អគ្គនាយកដ្ឋានរតនាគារជាតិ/រតនាគារ/ធនាគារ.......**



ឧបសម្ព័ន្ធទី ៣

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ស្ថាប័នអនុវត្តលទ្ធកម្ម/អង្គភាពថវិកា** .............

# លិខិតជូនដំណឹង

## ស្ដីពី

## ការអនុញ្ញាតដកប្រាក់កក់ធានាការដេញថ្លៃ

**សូមគោរពជូន**

**ឯកឧត្តមអគ្គនាយករតនាគារជាតិ/ លោក លោកស្រី ប្រធានរតនាគារ/ធនាគារ...........**

**កម្មវត្ថុ៖** សំណើសុំបង្វិលប្រាក់កក់ធានាការដេញថ្លៃស្ដីពី............... ជូនក្រុមហ៊ុន / សហគ្រាស.......

**យោង÷** លិខិតធានាប្រាក់កក់ធានាការដេញថ្លៃលេខ....... ចុះថ្ងៃទី..... ខែ..... ឆ្នាំ......របស់អគ្គនាយកដ្ឋានរតនាគារជាតិ/ រតនាគារ/ ធនាគារ.........

សេចក្ដីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ខ្ញុំសូមជម្រាបជូនឯកឧត្តមអគ្គនាយករតនាគារជាតិ/ លោក លោកស្រី ប្រធានរតនាគារ/ ធនាគារ.......... មេត្តាជ្រាបថា គណៈកម្មាធិការលទ្ធកម្ម/ ក្រុមលទ្ធកម្មបានវាយតម្លៃនិងជ្រើសរើសក្រុមហ៊ុន/ សហគ្រាស........ជាអ្នកដេញថ្លៃឈ្នះ ហើយក្រុមហ៊ុន/ សហគ្រាស........បានចុះកិច្ចសន្យាស្ដីពី.............រួចហើយ។

អាស្រ័យហេតុនេះសូមឯកឧត្តមអគ្គនាយករតនាគារជាតិ/............................ លោក ....... លោកស្រី ប្រធានរតនាគារ/ ធនាគារ........................ មេត្តាបង្វិលប្រាក់កក់ធានាការដេញថ្លៃដែលមានចំនួន......... ជូនក្រុមហ៊ុន/ សហគ្រាស.................. វិញតាមការគួរ។

សូមឯកឧត្តមអគ្គនាយករតនាគារជាតិ/ លោក លោកស្រី ប្រធានរតនាគារ/ ធនាគារ......... មេត្តាទទួលនូវការគោរពរាប់អានអំពីខ្ញុំ ។

.......,ថ្ងៃទី..... ខែ...... ឆ្នាំ.......

**ប្រធានគណៈកម្មាធិការលទ្ធកម្ម/ ក្រុមលទ្ធកម្ម**

**ចម្លងជូន៖**

- ក្រុមហ៊ុន/ សហគ្រាស........"ដើម្បីទៅដកប្រាក់កក់"
- ឯកសារកាលប្បវត្តិ

ឧបសម្ព័ន្ធទី ៤

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ស្ថាប័នអនុវត្តលទ្ធកម្ម/អង្គភាពថវិកា .............

# លិខិតជូនដំណឹង

## ស្តីពី

## ការអនុញ្ញាតដកប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា

សូមគោរពជូន

**ឯកឧត្តមអគ្គនាយករតនាគារជាតិ/ លោក លោកស្រី ប្រធានរតនាគារ/ធនាគារ...........**

**កម្មវត្ថុ៖** សំណើសុំបង្វិលប្រាក់កក់ធានាការអនុវត្តកិច្ចសន្យាស្តីពី.................ជូនក្រុមហ៊ុន / សហគ្រាស.........

**យោង៖** លិខិតធានាប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា លេខ.......ចុះថ្ងៃទី..... ខែ.....ឆ្នាំ......របស់អគ្គនាយកដ្ឋានរតនាគារជាតិ/ រតនាគារ/ធនាគារ......

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ខ្ញុំសូមជម្រាបជូនឯកឧត្តមអគ្គនាយករតនាគាជាតិ/ លោក លោកស្រី ប្រធានរតនាគារ/ធនាគារ..........មេត្តាជ្រាបថា ក្រុមហ៊ុន/សហគ្រាស.........បានបំពេញកាតព្វកិច្ចចប់សព្វគ្រប់ស្របតាមលក្ខខណ្ឌនៃកិច្ចសន្យាស្តីពី......................លេខ.....ចុះថ្ងៃទី....ខែ.....ឆ្នាំ២..... ។

អាស្រ័យហេតុនេះសូមឯកឧត្តមអគ្គនាយករតនាគាជាតិ/ លោក លោកស្រី ប្រធានរតនាគារ/ធនាគារ............ មេត្តាបង្វិលប្រាក់កក់ធានាការអនុវត្តកិច្ចសន្យាដែលមានចំនួន.........ជូនក្រុមហ៊ុន/ សហគ្រាស.........វិញតាមការគួរ។

សូមឯកឧត្តមអគ្គនាយករតនាគាជាតិ/លោក លោកស្រី ប្រធានរតនាគារ/ធនាគារ..........មេត្តាទទួលនូវការគោរពរាប់អានអំពីខ្ញុំ។

.......,ថ្ងៃទី.....ខែ......ឆ្នាំ......

**ប្រធានគណៈកម្មាធិការលទ្ធកម្ម/ក្រុមលទ្ធកម្ម**

ចម្លងជូន៖
- ក្រុមហ៊ុន/ សហគ្រាស........"ដើម្បីទៅដកប្រាក់កក់"
- ឯកសារកាលប្បវត្តិ

ឧបសម្ព័ន្ធទី ៥

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**ស្ថាប័នអនុវត្តលទ្ធកម្ម/អង្គភាពថវិកា .............**

## លិខិតជូនដំណឹង

## ស្តីពី

## ការរឹបអូសប្រាក់កក់ធានាការដេញថ្លៃ

**សូមគោរពជូន**

**ឯកឧត្តមអគ្គនាយករតនាគារជាតិ/ លោក លោកស្រី ប្រធានរតនាគារ/ធនាគារ...........**

**កម្មវត្ថុ៖** សំណើសុំរឹបអូសប្រាក់កក់ធានាការដេញថ្លៃស្តីពី................. របស់ក្រុមហ៊ុន / សហគ្រាស.............

**យោង ÷** លិខិតធានាប្រាក់កក់ធានាការដេញថ្លៃលេខ.......ចុះថ្ងៃទី.....ខែ.....ឆ្នាំ......របស់អគ្គនាយកដ្ឋានរតនាគារជាតិ/ រតនាគារ/ធនាគារ......

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ខ្ញុំសូមជម្រាបជូនឯកឧត្តមអគ្គនាយករតនាគារជាតិ/ លោក លោកស្រី ប្រធានរតនាគារ/ធនាគារ...........មេត្តាជ្រាបថា ក្រុមហ៊ុន/ សហគ្រាស........បានដកសំណើដេញថ្លៃរបស់ខ្លួនវិញក្នុងរយៈពេលសុពលភាពនៃសំណើដេញថ្លៃ/មិនព្រមផ្តល់លិខិតធានាប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា/ មិនព្រមចុះកិច្ចសន្យាក្នុងរយៈពេលដែលបានកំណត់ក្នុងលិខិតស្តីពីការអញ្ជើញចុះកិច្ចសន្យា។

អាស្រ័យហេតុនេះសូមឯកឧត្តមអគ្គនាយករតនាគារជាតិ/លោក លោកស្រី ប្រធានរតនាគារ/ធនាគារ....... មេត្តាបង្វិលប្រាក់កក់ធានាការដេញថ្លៃដែលមានចំនួន..............ចូលគណនីលេខ..............របស់........................... .............. តាមការគួរ។

សូមឯកឧត្តមអគ្គនាយករតនាគារជាតិ/ លោក លោកស្រី ប្រធានរតនាគារ/ធនាគារ..........មេត្តាទទួលនូវការគោរពរាប់អានអំពីខ្ញុំ ។

.......,ថ្ងៃទី.....ខែ......ឆ្នាំ.......

**ប្រធានគណៈកម្មាធិការលទ្ធកម្ម/ក្រុមលទ្ធកម្ម**

**ចម្លងជូន៖**
-ក្រុមហ៊ុន/ សហគ្រាស.......
-ឯកសារកាលប្បវត្តិ

ឧបសម្ព័ន្ធទី ៦

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ស្ថាប័នអនុវត្តលទ្ធកម្ម/អង្គភាពថវិកា** .............

# លិខិតជូនដំណឹង

## ស្តីពី

## ការរឹបអូសប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា

**សូមគោរពជូន**

**ឯកឧត្តមអគ្គនាយករតនាគារជាតិ/ លោក លោកស្រី ប្រធានរតនាគារ/ធនាគារ...........**

**កម្មវត្ថុ៖** សំណើសុំរឹបអូសប្រាក់កក់ធានាការអនុវត្តកិច្ចសន្យាស្តីពី.............របស់ក្រុមហ៊ុន / សហគ្រាស............

**យោង÷** លិខិតធានាប្រាក់កក់ធានាការអនុវត្តកិច្ចសន្យាលេខ.........ចុះថ្ងៃទី.....ខែ.....ឆ្នាំ......របស់អគ្គនាយកដ្ឋានរតនាគារជាតិ/ រតនាគារ/ធនាគារ.......

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ខ្ញុំសូមជម្រាបជូនឯកឧត្តមអគ្គនាយករតនាគាជាតិ/ លោក លោកស្រី ប្រធានរតនាគារ/ធនាគារ.............មេត្តាជ្រាបថា ក្រុមហ៊ុន/ សហគ្រាស...........មិនបានបំពេញកាតព្វកិច្ចត្រឹមត្រូវតាមលក្ខខណ្ឌនៃកិច្ចសន្យាស្តីពី............លេខ.....ចុះថ្ងៃទី....ខែ.....ឆ្នាំ......ហើយត្រូវបាន.....(បញ្ចូលឈ្មោះស្ថាប័នអនុវត្តលទ្ធកម្ម/អង្គភាពថវិកា)... បញ្ចប់កិច្ចសន្យានេះជាស្ថាពររួចហើយ។

អាស្រ័យហេតុនេះសូមឯកឧត្តមអគ្គនាយករតនាគាជាតិ/ លោក លោកស្រី ប្រធានរតនាគារ/ធនាគារ.............មេត្តាបង្វិលប្រាក់កក់ធានាការអនុវត្តកិច្ចសន្យាដែលមានចំនួន.........ចូលគណនីលេខ............របស់...............តាមការគួរ។

សូមឯកឧត្តមអគ្គនាយករតនាគាជាតិ/លោក លោកស្រី ប្រធានរតនាគារ/ធនាគារ...............មេត្តាទទួលនូវការគោរពរាប់អានអំពីខ្ញុំ។

.......,ថ្ងៃទី.....ខែ......ឆ្នាំ......

**ប្រធានគណៈកម្មាធិការលទ្ធកម្ម/...**

**ចម្លងជូន:**

- ក្រុមហ៊ុន/ សហគ្រាស........
- ឯកសារកាលប្បវត្តិ